**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស**
លេខ: ០១១/១៤ ស.ហ.ក ពបហ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
# ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០១៤

នៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០១៤ វេលាម៉ោង ៨ និង ៣០ នាទី នៅវិមានសន្តិភាពមានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងអាណត្តិទី៥ ដើម្បីឆ្លងៈ

**១- សេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់។**
**២- សេចក្តីព្រាងផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៤-២០១៨។**
**៣- បញ្ហាផ្សេងៗ**

## ១- សេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់

ថ្នាំជក់ ជាមូលហេតុចម្បងដែលនាំឲ្យកើតជំងឺមហារីក។ នៅប្រទេសកម្ពុជា ប្រាក់ជិត ១០០លានដុល្លារសហរដ្ឋអាមេរិក ត្រូវបានប្រើប្រាស់សម្រាប់ទិញបារីជក់ក្នុង១ឆ្នាំៗ ហើយការចំណាយទៅលើការព្យាបាលជំងឺដែលបង្កដោយការជក់បារី មានទំហំធំជាងប្រាក់ចំណាយទៅលើការទិញបារីឆ្ងាយណាស់។

ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន ចូលជាសមាជិកអនុសញ្ញា ស្តីពីការត្រួតពិនិត្យថ្នាំជក់របស់អង្គការសុខភាពពិភពលោកនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៥។ អនុសញ្ញានេះ ត្រូវបានបង្កើតឡើងដើម្បីការពារមនុស្សជំនាន់បច្ចុប្បន្ន និងជំនាន់ក្រោយពីមហន្តរាយ សុខភាព បរិស្ថាន និងសេដ្ឋកិច្ច ដែលបង្កដោយការប្រើប្រាស់ថ្នាំជក់។

ក្នុងនាមជារដ្ឋភាគីនៃអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់ ព្រះរាជាណាចក្រកម្ពុជា ត្រូវមានកាតព្វកិច្ចអនុវត្តតាមវិធានការនានា ដែលបានលើកឡើងក្នុងអនុសញ្ញាសំដៅកាត់បន្ថយការប្រើប្រាស់ថ្នាំជក់។

សេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យថ្នាំជក់ ដែលត្រូវបានរៀបចំឡើងដោយក្រសួងសុខាភិបាល មានគោលបំណងកំណត់វិធានការដើម្បីត្រួតពិនិត្យផលិតផលថ្នាំជក់ និងកាត់បន្ថយផលប៉ះពាល់ដល់សុខភាព សេដ្ឋកិច្ច សង្គម និងបរិស្ថាន។

សេចក្តីព្រាងច្បាប់នេះ មាន ១៣ជំពូក ៥៩មាត្រា។

**២- សេចក្តីព្រាងផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៤-២០១៨។**

អំពើហិង្សាលើស្ត្រី និងកុមារី គឺជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិស្ត្រី និងកុមារី ដែលជាសិទ្ធិមនុស្ស ដោយបានដាក់សម្ពាធទៅលើសន្តិសុខរបស់ស្ត្រី និងកុមារី ក៏ដូចជាការបែងចែកសិទ្ធិអំណាចនៅក្នុងសម្ព័ន្ធភាពរវាងបុរស និងស្ត្រី នៅក្នុង និងនៅក្រៅផ្ទះ ដែលជាមូលហេតុចម្បងបង្កឲ្យមានអំពើហិង្សាលើស្ត្រី ហើយក៏ជាឧបសគ្គដ៏ធ្ងន់ធ្ងរមួយ សម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅកម្ពុជាផងដែរ។

ដូច្នេះការទប់ស្កាត់ និងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រីប្រកបដោយប្រសិទ្ធភាព តម្រូវឲ្យមានវិធីសាស្ត្រសម្របសម្រួលអន្តរវិស័យមួយជាចាំបាច់ ដែលមានលក្ខណៈរួមបញ្ចូលគ្នា និងគ្រប់ជ្រុងជ្រោយ។ ស្ថាប័នពាក់ព័ន្ធទាំងអស់ ដូចជា ស្ថាប័នជាតិ សង្គមស៊ីវិល អង្គការស្ត្រី សហគមន៍ អ្នកផ្តល់សេវាកម្ម ក្រុមយុវជន ស្ត្រី និងបុរស កុមារី និងកុមារា រួមទាំងក្រុមសាសនាផ្សេងៗ ត្រូវចូលរួមក្នុងសកម្មភាពនេះ។

ក្រសួងកិច្ចការនារី ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជា បានដឹកនាំ និងសម្របសម្រួលដំណើរការ នៃការរៀបចំសេចក្តីព្រាងផែនការសកម្មភាពជាតិឆ្នាំ២០១៤-២០១៨ ដោយផ្អែកលើបទពិសោធន៍ នៃការរៀបចំផែនការសកម្មភាពជាតិឆ្នាំ២០០៩-២០១២។

គោលបំណងជាយុទ្ធសាស្ត្ររួមនៃផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៤-២០១៨ គឺដើម្បីកាត់បន្ថយអំពើហិង្សាគ្រប់បែបយ៉ាងប្រឆាំងស្ត្រី និងកុមារី ដោយរួមបញ្ចូលទាំងអ្នកដែលមានហានិភ័យខ្ពស់ តាមរយៈកិច្ចអន្តរាគមន៍ទប់ស្កាត់ ការឆ្លើយតប ការទទួលបានសេវាកម្មប្រកបដោយគុណភាព និងការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការជាពហុវិស័យកាន់តែប្រសើរឡើង។

ក្នុងការផ្តល់សេវាកម្ម កម្ពុជានឹងឈានទៅបង្កើតមជ្ឈមណ្ឌលផ្តល់សេវាកម្មចម្រុះសម្រាប់ជនរងគ្រោះដោយអំពើហិង្សា ទាក់ទងនឹងយេនឌ័រ ដែលមានកិច្ចសហការ និងសហប្រតិបត្តិការពីសំណាក់ស្ថាប័នពាក់ព័ន្ធចម្បងៗ ដើម្បីផ្តល់នូវកិច្ចអន្តរាគមន៍ជួយជនរងគ្រោះឲ្យបានល្អប្រសើរជាងមុន។ ក្រៅពីនេះ ការប្រមូល និងតាមដានទិន្នន័យដ៏ច្បាស់លាស់មួយនឹងត្រូវបានបង្កើតឡើង និងយកទៅអនុវត្ត ដើម្បីពិនិត្យតាមដាន និងវាយតម្លៃផែនការសកម្មភាពជាតិឆ្នាំ២០១៤-២០១៨ នេះផងដែរ។

**៣- បញ្ហាផ្សេងៗ**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានណែនាំឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដឹកនាំកិច្ចប្រជុំអន្តរក្រសួងមួយ ដោយមានការចូលរួមពីក្រសួងព័ត៌មាន ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងពាណិជ្ជកម្ម ក្រសួងធម្មការនិងកិច្ចការសាសនា ក្រសួងទេសចរណ៍ និងស្ថាប័នពាក់ព័ន្ធ ដើម្បីរិះរកវិធីជំរុញលើកទឹកចិត្តដល់ការផលិតខ្សែភាពយន្ត និងសិល្បៈខ្មែរ ទាំងបរិមាណ និងគុណភាព ក្នុងគោលដៅកាត់បន្ថយការនាំចូលសិល្បៈភាពយន្តពីបរទេស។

កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង ១១ និង ៣០នាទី

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០១៤